ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..ធ៥..០១៧...០០៩...០៩.១.១...ណ.ក.ចា.ស

# សេចក្តីណែនាំ
# ស្តីពី
# ការបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យរបស់បុគ្គលរាយការណ៍
# ស្ថិតក្រោមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់
# និងហិរញ្ញប្បទានភេរវកម្ម

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

# តារាងមាតិកា


| | ទំព័រ |
|---|---|
| I- សារតា | ២ |
| II- គោលបំណង | ២ |
| III- របាយការណ៍ប្រតិបត្តិការសង្ស័យ | ៣ |
| **ផ្នែកទី១៖ របៀបបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យ** | ៣ |
| ១- ការបញ្ជូនតាមអេឡិចត្រូនិក | ៣ |
| ២- គុណសម្បត្តិនៃការរាយការណ៍តាមប្រព័ន្ធអេឡិចត្រូនិក | ៣ |
| **ផ្នែកទី២៖ ទម្រង់មូលដ្ឋាននៃរបាយការណ៍ប្រតិបត្តិការសង្ស័យ** | ៣ |
| ១- ត្រូវឲ្យខ្លីនិងមានន័យច្បាស់លាស់ | ៤ |
| ២- សេចក្ដីលម្អិតនៃការសង្ស័យ | ៤ |
| ៣- បំពេញព័ត៌មានឱ្យបានគ្រប់ចំណុចនៃរបាយការណ៍ប្រតិបត្តិការសង្ស័យ | ៥ |
| ៤- អតិថិជនជាឯកត្តបុគ្គល | ៥ |
| ៥- អតិថិជនជានីតិបុគ្គល បរធនបាលកិច្ច និងអង្គភាពផ្សេងទៀត | ៦ |
| ៦- ប្រតិបត្តិការហិរញ្ញវត្ថុ | ៧ |
| ៧- លេខសម្គាល់បុគ្គលរាយការណ៍ | ៧ |
| ៨- ឯកសារភ្ជាប់ | ៨ |
| ៩- ដីកាតុលាការ និងការសាកសួរព័ត៌មានពីភ្នាក់ងារអនុវត្តច្បាប់ | ៨ |
| **ផ្នែកទី៣៖ សេចក្ដីណែនាំទូទៅ** | ៨ |
| ១- ការបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យ | ៨ |
| ២- ចំណុចត្រូវចងចាំ | ៨ |
| **ផ្នែកទី៤៖ ព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនង** | ៩ |
| **ផ្នែកទី៥៖ គន្លឹះសម្រាប់អនុវត្តឱ្យបានល្អប្រសើរ** | ៩ |
| **ផ្នែកទី៦៖ ឧទាហរណ៍** | ១០ |
| ឧបសម្ព័ន្ធ | ១៣ |

## I- សាវតា

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៨ ជាស្ថាប័នកណ្តាលដែលទទួលខុសត្រូវក្នុងការទទួល វិភាគ និងបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យនិងប្រតិបត្តិការសាច់ប្រាក់ និងព័ត៌មានផ្សេងទៀត ដែលពាក់ព័ន្ធនឹងការសម្អាតប្រាក់ និង/ឬហិរញ្ញប្បទានភេរវកម្ម។

យោងតាមមាត្រា ២២.១ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ស.ហ.ក ត្រូវចេញសេចក្តីណែនាំទៅបុគ្គលរាយការណ៍អំពីការកំណត់អត្តសញ្ញាណអតិថិជន ការកត់ត្រាប្រតិបត្តិការ ការរាយការណ៍ប្រតិបត្តិការសង្ស័យ និងកាតព្វកិច្ចផ្សេងទៀតស្របតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

## II- គោលបំណង

សេចក្តីណែនាំនេះ មានបំណងពន្យល់បន្ថែមដល់បុគ្គលរាយការណ៍ទាំងអស់អំពីរបៀបបញ្ជូនរបាយការណ៍ប្រតិបត្តិសង្ស័យមក ស.ហ.ក។ សេចក្តីណែនាំនេះ ត្រូវបានធ្វើឡើងស្របតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០០៧ ប្រកាសឆ្នាំ២០០៨ សម្រាប់បុគ្គលរាយការណ៍ស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ប្រកាសឆ្នាំ២០១០ សម្រាប់បុគ្គលរាយការណ៍មិនស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា និងសេចក្តីណែនាំអំពីការអនុវត្តការរាយការណ៍ប្រតិបត្តិការសង្ស័យ និងប្រតិបត្តិការសាច់ប្រាក់ តាមប្រព័ន្ធអេឡិចត្រូនិក។

សេចក្តីណែនាំនេះ អាចធ្វើឱ្យ ស.ហ.ក ទទួលបានព័ត៌មានច្រើនអំពី៖

- អត្តសញ្ញាណជនសង្ស័យ
- អត្តសញ្ញាណជនសមគំនិត
- កាលបរិច្ឆេទធ្វើប្រតិបត្តិការ
- មូលហេតុនៃការធ្វើប្រតិបត្តិការ
- ទីកន្លែងធ្វើប្រតិបត្តិការ
- វិធីសាស្ត្រធ្វើប្រតិបត្តិការ

ព័ត៌មានទាំងនេះអាចឱ្យ ស.ហ.ក កំណត់អាទិភាពនៃការវិភាគប្រតិបត្តិការសង្ស័យ និងបញ្ជូនទៅអាជ្ញាធរស៊ើបអង្កេតបានទាន់ពេលវេលា។ នៅពេលបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យមក ស.ហ.ក បុគ្គលរាយការណ៍ត្រូវផ្អែកលើសេចក្តីណែនាំដែលបានផ្សព្វផ្សាយដោយ ស.ហ.ក និងសេចក្តីណែនាំផ្ទៃក្នុងរបស់ខ្លួន។

**សម្គាល់៖** បុគ្គលរាយការណ៍ទាំងអស់ត្រូវបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យស្របតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០០៧ ដែលបានកំណត់ចំណុចមួយចំនួនដូចខាងក្រោម៖

- អត្តសញ្ញាណសម្គាល់បុគ្គលរាយការណ៍ រួមទាំងឈ្មោះនិងព័ត៌មានលម្អិតសម្រាប់ទាក់ទងមន្ត្រីរាយការណ៍[1]

[1] សូមចូលមើលទម្រង់ប្រតិបត្តិការសង្ស័យ

- អត្តសញ្ញាណសម្គាល់របស់អតិថិជន និងអត្តគាហកដែលពាក់ព័ន្ធក្នុងប្រតិបត្តិការ
- ប្រភេទនិងព័ត៌មានលម្អិតនៃប្រតិបត្តិការដូចជា ចំនួនទឹកប្រាក់ ប្រភេទរូបិយប័ណ្ណ កាលបរិច្ឆេទ ភាគីពាក់ព័ន្ធដែលត្រូវបានរាយការណ៍ថាសង្ស័យ រួមមាន លេខគណនី សញ្ញាណសម្គាល់ម្ចាស់គណនី និង
- ពិពណ៌នាដោយសង្ខេបអំពីកាលៈទេសៈ និងហេតុផលផ្សេងៗដែលបង្ហាញឱ្យឃើញថាជាប្រតិបត្តិការសង្ស័យ។

រាល់ការរាយការណ៍ត្រូវធ្វើឡើងឲ្យស្របតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០០៧ និងផ្អែកលើការយល់ដឹង ការជឿជាក់ ឬការសង្ស័យ។

## III- របាយការណ៍ប្រតិបត្តិការសង្ស័យ

ប្រតិបត្តិការសង្ស័យ ជាប្រតិបត្តិការទាក់ទងនឹងមូលនិធិដែលត្រូវបានសង្ស័យថា បានមកពីការប្រព្រឹត្តបទល្មើស ឬ ជាមូលនិធិទាក់ទងនឹងហិរញ្ញប្បទានភេរវកម្ម។ ការរាយការណ៍ប្រតិបត្តិការសង្ស័យ គឺដោយសារអ្នកបានដឹង ឬសង្ស័យថាមានការសម្អាតប្រាក់ ឬមួយអ្នកជឿជាក់ ឬសង្ស័យថាមានពាក់ព័ន្ធនឹងហិរញ្ញប្បទានភេរវកម្ម។

### ផ្នែកទី១៖ របៀបបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យ

#### ១- ការបញ្ជូនតាមអេឡិចត្រូនិក

ការរៀបចំនិងបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យ តាមប្រព័ន្ធអេឡិចត្រូនិក គឺមានសុវត្ថិភាពខ្ពស់។ បុគ្គលរាយការណ៍អាចចូលយកសេចក្តីណែនាំអំពីការរាយការណ៍តាមអេឡិចត្រូនិកពីគេហទំព័រ https://www.nbc.org.kh/cafiu របស់ ស.ហ.ក បាន។

#### ២- គុណសម្បត្តិនៃការរាយការណ៍តាមប្រព័ន្ធអេឡិចត្រូនិក

- ចំណាយតិច និងមានសុវត្ថិភាព
- កាត់បន្ថយការរាយការណ៍ឯកសារជាក្រដាស
- នៅពេលបញ្ជូនរបាយការណ៍ មានការបញ្ជាក់ការទទួលបាន ដោយមានលេខយោងជាក់លាក់ដែលបញ្ជូនត្រលប់ទៅវិញតាមអ៊ីម៉ែល
- ការរាយការណ៍អាចធ្វើឡើង ២៤ម៉ោង ក្នុងមួយថ្ងៃ និង ៧ថ្ងៃ ក្នុងមួយសប្តាហ៍ ដោយគ្រាន់តែមានអ៊ីនធឺណែត និងអ៊ីម៉ែល
- មានរំលេចប្រាប់គម្រុយ (Tips) នៅក្នុងទម្រង់ប្រតិបត្តិការសង្ស័យ
- ចំណេញពេលវេលា

### ផ្នែកទី២៖ ទម្រង់មូលដ្ឋាននៃរបាយការណ៍ប្រតិបត្តិការសង្ស័យ

ចំណុចដែលត្រូវបំពេញ ត្រូវធ្វើតាមដំណាក់កាលខាងក្រោម៖

- បំពេញព័ត៌មានឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន នៅក្នុងរបាយការណ៍ប្រតិបត្តិការសង្ស័យ
- ប្រតិបត្តិការសង្ស័យត្រូវរាប់បញ្ចូលព័ត៌មានការយកចិត្តទុកដាក់ស្គាល់អតិថិជន

- ថ្ងៃ ខែ ឆ្នាំកំណើត គឺជាចំណុចសំខាន់សម្រាប់កំណត់អត្តសញ្ញាណបុគ្គលបានឱ្យត្រឹមត្រូវ
- បន្ថែមលើ 'មូលហេតុនៃការសង្ស័យ' សូមបំពេញគ្រប់ចំណុចនៅក្នុងរបាយការណ៍ប្រតិបត្តិការសង្ស័យ

ព័ត៌មានដែលត្រូវបំពេញក្នុងរបាយការណ៍ប្រតិបត្តិការសង្ស័យ ជួយធ្វើឱ្យប្រតិបត្តិការសង្ស័យកាន់តែមានគុណភាពផង និងផ្ទៀងអត្តសញ្ញាណ 'ជនជាកម្មវត្ថុនៃការសង្ស័យ' ឲ្យបានត្រឹមត្រូវផង។ ព័ត៌មានមិនគ្រប់គ្រាន់ ឬព័ត៌មានមិនត្រឹមត្រូវៈ

- ធ្វើឲ្យគុណភាពនៃការវិភាគមានកម្រិត
- ពិបាកក្នុងការកំណត់អត្តសញ្ញាណ 'ជនជាកម្មវត្ថុនៃការសង្ស័យ' ឱ្យបានត្រឹមត្រូវ
- កាត់បន្ថយគុណភាពរួមនៃប្រតិបត្តិការសង្ស័យ

**១- ត្រូវឲ្យខ្លី និងមានន័យច្បាស់លាស់ៈ**

ហេតុផលជាក់ស្តែងនៅពីក្រោយការសង្ស័យ ដែលនាំទៅដល់ការសម្រេចចិត្តបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យមក ស.ហ.ក ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់។

- រៀបចំរចនាសម្ព័ន្ធក្នុងទម្រង់មួយសមស្រប និងរៀបរាប់បញ្ចូលព័ត៌មានពាក់ព័ន្ធទាំងអស់
- សង្ខេបការសង្ស័យឱ្យខ្លី
- បរិយាយតាមលំដាប់នៃព្រឹត្តិការណ៍
- សរសេរខ្លឹមសារឲ្យសាមញ្ញ ច្បាស់លាស់ និងមានន័យគ្រប់គ្រាន់
- ចៀសវាងការសរសេរពាក្យកាត់ ដែលអាចឲ្យអ្នកអានយល់ច្រឡំ និងបកស្រាយខុស
- កុំប្រើអក្សរធំ (CAPITAL LETTERS) ព្រោះអក្សរធំ (CAPITAL LETTERS) ពិបាកអាន
- បើមានព័ត៌មានច្រើនត្រូវសរសេរបញ្ចូល សូមព្យាយាមបំបែកជាកថាខ័ណ្ឌផ្សេងៗគ្នា
- របាយការណ៍ប្រតិបត្តិការសង្ស័យដែលសរសេរវែងពេក អ្នកអាននឹងពិបាកយល់
- បំបែកលេខគណនីធនាគារ និងព័ត៌មានប្រតិបត្តិការឲ្យដាច់ពីគ្នា និងសូមប្រើលេខ និងទម្រង់គណនីស្តង់ដា ដូចជា ០១២៣៤៥៦៧៨៩១០។

**២- សេចក្តីលម្អិតនៃការសង្ស័យ**

សេចក្តីលម្អិតនៃការសង្ស័យ ត្រូវបញ្ជាក់មូលហេតុអំពីការរាយការណ៍ប្រតិបត្តិការសង្ស័យ ដូច្នេះ ត្រូវរៀបរាប់ពីមូលហេតុឲ្យបានច្បាស់លាស់។

ត្រង់ចំណុច 'មូលហេតុនៃការសង្ស័យ' ចូរសរសេរអំពីៈ

- អ្នកណាខ្លះដែលពាក់ព័ន្ធ?
- តើពួកគេពាក់ព័ន្ធយ៉ាងដូចម្តេច?
- តើទ្រព្យសម្បត្តិរបស់ឧក្រិដ្ឋជន/ភេរវករ មានអ្វីខ្លះ?
- តើទ្រព្យសម្បត្តិរបស់ឧក្រិដ្ឋជន/ភេរវករ មានតម្លៃប៉ុន្មាន (អាចប៉ាន់ស្មានបាន)?
- តើទ្រព្យសម្បត្តិរបស់ឧក្រិដ្ឋជន/ភេរវករ មាននៅទីណាខ្លះ (ឧទាហរណ៍ មានក្រុមហ៊ុនមួយនៅភ្នំពេញ, មានអចលនទ្រព្យមួយកន្លែងនៅសៀមរាប។ល។)
- តើកាលៈទេសៈនោះបានកើតឡើងនៅពេលណា?

- តើកាលៈទេសៈនោះគ្រោងនឹងកើតឡើងពីពេលណា?
- តើកាលៈទេសៈនោះបានកើតឡើងយ៉ាងដូចម្តេច?
- ហេតុអ្វីបានជាអ្នកសង្ស័យ ឬបានដឹង?

ចំណុចសង្ស័យជាកត្តាសំខាន់ សម្រាប់ធ្វើសំណើសុំព័ត៌មានអំពីបទល្មើសសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម ហើយក៏សំខាន់ចំពោះអ្នកវិភាគក្នុងការវិភាគព័ត៌មានផងដែរ។

កិច្ចការវិភាគភាគច្រើនផ្តោតលើការស្វែងរកពាក្យគន្លឹះ ដែលបំពេញនៅតាមចំណុចនីមួយៗ។ ទោះជាចំណុចផ្សេងទៀតមិនបានតម្រូវឲ្យបំពេញជាកំហិតក៏ដោយ ក៏ត្រង់ចំណុចសង្ស័យនេះត្រូវតែបំពេញឲ្យបានលម្អិតច្បាស់លាស់។

ស.ហ.ក ទទួលស្គាល់ថាការសរសេររបាយការណ៍ឲ្យបានលម្អិតត្រូវចំណាយពេលច្រើន ក៏ប៉ុន្តែ ការបំពេញរបាយការណ៍ប្រតិបត្តិការសង្ស័យ ចាំបាច់ត្រូវតែបំពេញឲ្យបានគ្រប់ជ្រុងជ្រោយតាមចំណុចនីមួយៗនៅក្នុងរបាយការណ៍តាមជំហានៗដូចខាងក្រោម មិនមែនបំពេញតែនៅចំណុច 'មូលហេតុនៃការសង្ស័យ' ទេ។ ការបំពេញព័ត៌មានឱ្យបានគ្រប់ចំណុចមានសារៈសំខាន់ ព្រោះប្រព័ន្ធ IT របស់ ស.ហ.ក ត្រូវការភ្ជាប់ព័ត៌មានគ្រឹះស្ថានផ្សេងៗ ដែលបញ្ជូនរបាយការណ៍មក ជាពិសេសព័ត៌មានគណនីធនាគារ។

**ជំហានទី១ ៖** ដំបូងសូមសង្ខេបចំណុចសំខាន់ៗនៃការសង្ស័យ

*ឧទាហរណ៍ ខ្ញុំបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យនេះ ដោយសារអតិថិជនកំពុងទិញអចលនទ្រព្យមួយកន្លែង ដោយប្រើមូលនិធិពីបរទេសដែលមានប្រភពមិនច្បាស់លាស់។ កាលៈទេសៈដែលនាំទៅដល់ការសង្ស័យថាមានការសម្អាតប្រាក់គឺ...*

*អតិថិជននេះមានជាប់ពាក់ព័ន្ធការផ្សាយព័ត៌មានថាបានរួមចំណែកក្នុងការបំប្លែង បិទបាំង និងការផ្ទេរមូលនិធិ ដែលបានពីផលនៃបទល្មើស និងអំពើពុករលួយ។ គាត់គឺជាបុគ្គលពាក់ព័ន្ធនយោបាយបរទេស។ កាលៈទេសៈដែលនាំទៅដល់ការសង្ស័យថាមានការសម្អាតប្រាក់គឺ...*

**ជំហានទី២ ៖** ពិនិត្យរកព័ត៌មានពាក់ព័ន្ធផ្សេងៗ ដែលអាចផ្តល់ឲ្យបន្ថែមទៀតបាន។

**ជំហានទី៣៖** នៅចុងកថាខ័ណ្ឌនៃ 'មូលហេតុនៃការសង្ស័យ' គួរបញ្ជាក់អំពីចំណាត់ការបន្ទាប់ដែលគ្រឹះស្ថានប៉ងធ្វើ *ឧទារហរណ៍ ផ្តាច់ទំនាក់ទំនងជាមួយអតិថិជន, បន្តតាមដានអតិថិជន, ឬបន្តទំនាក់ទំនងជាធម្មតាជាមួយអតិថិជន។ល។*

### ៣- បំពេញឱ្យបានគ្រប់ចំណុចទាំងអស់នៃរបាយការណ៍ប្រតិបត្តិការសង្ស័យ

ជាមួយនឹងការបំពេញអំពី 'មូលហេតុនៃការសង្ស័យ' សូមអ្នកបំពេញព័ត៌មានផ្សេងទៀតឱ្យបានគ្រប់តាមដែលអាចធ្វើទៅបាន ដែលអ្នកប្រមូលបានពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន។

ព័ត៌មានអំពីអតិថិជនមានច្រើនឬតិច អាស្រ័យលើទំនាក់ទំនងជាមួយអតិថិជន។

បើមានចំណុចណាដែលអ្នកមិនមានព័ត៌មានសម្រាប់បំពេញ សូមសរសេរ 'N/A' នៅទីនោះ។

### ៤- អតិថិជនជាឯកត្តបុគ្គល

សូមបញ្ជាក់អត្តសញ្ញាណទាំងអស់ ដូចខាងក្រោម៖

ព័ត៌មានឯកកត្តបុគ្គល ឬបុគ្គលពាក់ព័ន្ធនយោបាយ

- ឈ្មោះពេញ
- ថ្ងៃខែឆ្នាំកំណើត
- សញ្ជាតិ
- អាសយដ្ឋាន

នៅត្រង់ចំណុចសង្ស័យ សូមបំពេញព័ត៌មាន ដូចខាងក្រោម ប្រសិនបើមាន៖

- ឯកសារអត្តសញ្ញាណអតិថិជន (រួមទាំង លេខសម្គាល់ឯកសារ) ឧទាហរណ៍ លេខអត្តសញ្ញាណប័ណ្ណ, លិខិតឆ្លងដែន, ប័ណ្ណបើកបរ, លេខធានារ៉ាប់រង។ល។
- ព័ត៌មានអំពីយានយន្ត (ស្លាកលេខរថយន្ត។ល។)
- លេខទូរស័ព្ទ (សូមបញ្ជាក់ជាលេខទូរស័ព្ទដៃ លេខផ្ទះ ឬកន្លែងធ្វើការ)
- ព័ត៌មានលម្អិតអំពីគណនីធនាគារ ឬព័ត៌មានហិរញ្ញវត្ថុ (រួមទាំងលេខគណនី។ល។) សូមប្រើលេខ និងទម្រង់គណនីស្តង់ដា ដូចជា ០១២៣៤៥៦៧៨៩១០។
- មុខរបរ។

នៅពេលផ្តល់ព័ត៌មានលម្អិតអំពីមុខរបររបស់ 'ជនជាកម្មវត្ថុនៃការសង្ស័យ' អាចជួយសម្រួលដល់ការងារអ្នកវិភាគបានក្នុងការ៖

- វិនិច្ឆ័យអំពីប្រភពទុន
- កំណត់ថាអតិថិជនកំពុងប្រើចំណេះដឹងវិជ្ជាជីវៈរបស់ខ្លួន ដើម្បីជួយសម្របសម្រួលការសម្អាតប្រាក់ឬយ៉ាងណា? ព្រមទាំងអាចកំណត់អត្តសញ្ញាណជាមួយនិយ័តករ ឬអ្នកត្រួតពិនិត្យដែលត្រូវសហការ?

ស.ហ.ក ទទួលស្គាល់ថាបុគ្គលរាយការណ៍អាចនឹងមិនមានព័ត៌មានពេញលេញរបស់អតិថិជនពាក់ព័ន្ធទាំងឡាយគ្រប់ពេលនោះទេ ជាពិសេស បើសិនជាអតិថិជននោះមិនមែនជាអតិថិជនអចិន្ត្រៃយ៍របស់អ្នក។

**៥- អតិថិជនជានីតិបុគ្គល បរធនបាលកិច្ច និងអង្គភាពផ្សេងៗ**

ព័ត៌មាន ត្រូវមាន៖

- ឈ្មោះនីតិបុគ្គល
- ប្រភេទនីតិបុគ្គល ឧទាហរណ៍ ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត សាជីវកម្ម។ល។
- ឈ្មោះពាណិជ្ជកម្ម
- លេខចុះបញ្ជី
- លេខយោងពន្ធ ឬអាករលើតម្លៃបន្ថែម (VAT)
- ប្រទេសបង្កើតក្រុមហ៊ុន
- ព័ត៌មានលម្អិតរបស់អត្តគាហក
- បុគ្គល/ក្រុមហ៊ុន ដែលមានតួនាទីជានាយក (ឬមានឋានៈស្មើ)
- អតិថិជនជាបុគ្គល ដែលកាន់កាប់ / ត្រួតត្រា / ធ្វើប្រតិបត្តិការក្នុងការគ្រប់គ្រងលើក្រុមហ៊ុន។

ចំពោះបរធនបាលកិច្ច សូមបញ្ជាក់អត្តសញ្ញាណទាំងអស់ ដូចខាងក្រោម៖

- ឈ្មោះពេញរបស់បរធនបាលកិច្ច

- អាសយដ្ឋាន
- លក្ខណៈ និងប្រភេទនៃបរធនបាលកិច្ច

សូមផ្តល់ព័ត៌មានលម្អិតរបស់បរធនបាលក្នុងការមើលថែរក្សា (Trustees) បរធនបាលទាយក (Settlors/Protectors) និងអត្ថគាហក ប្រសិនបើព័ត៌មាននេះពាក់ព័ន្ធនឹងការសង្ស័យ។

**៦- ប្រតិបត្តិការហិរញ្ញវត្ថុ**

នៅពេលមានការសង្ស័យពាក់ព័ន្ធនឹងប្រតិបត្តិការហិរញ្ញវត្ថុ ត្រូវបញ្ចូលព័ត៌មានដូចខាងក្រោម៖

- ព័ត៌មានលម្អិតរបស់អត្ថគាហក/អ្នកផ្ញើប្រាក់
- ព័ត៌មានលម្អិតរបស់ធនាគារផ្ទេរប្រាក់ និងធនាគារទទួលប្រាក់។ ឧទាហរណ៍ ធនាគារទំនាក់ទំនង (ចំណុចនេះមានសារៈសំខាន់ ព្រោះវាអាចកំណត់អត្តសញ្ញាណអ្នកប្រព្រឹត្តបទល្មើស)
- កាលបរិច្ឆេទនៃប្រតិបត្តិការបានកើតឡើង ឬ នឹងកើតឡើង
- បញ្ជាក់ពីប្រភេទនៃប្រតិបត្តិការ ដូចជា៖
    - ការទទួល/ទូទាត់ប្រាក់តាមអនឡាញ
    - ការប្រើប្រាស់កាតឥណពន្ធ ឬឥណទាន
    - ការដកប្រាក់តាមម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ
    - ការប្រើប្រាស់មូលប្បទានបត្រ
    - ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក
    - ការប្រើប្រាស់សាច់ប្រាក់
- ពន្យល់អំពីមូលហេតុដែលប្រតិបត្តិការគួរឲ្យសង្ស័យ
- ព័ត៌មានហិរញ្ញវត្ថុរបស់ 'ជនជាកម្មវត្ថុនៃការសង្ស័យ' (លេខគណនី) និងព័ត៌មានរបស់សមាគត
- សង្ខេបនូវចំនួនសាច់ប្រាក់នៅចុងបញ្ចប់នៃរបាយការណ៍។

សូមពន្យល់ពីភាពខុសគ្នា បើសិនជាអ្នកមានការសង្ស័យដោយសារសកម្មភាពដែលបានកើតឡើងមិនសមស្របទៅនឹងសកម្មភាពប្រចាំថ្ងៃរបស់អតិថិជន/អាជីវកម្ម។

សូមផ្តល់ព័ត៌មានលម្អិតរបស់បុគ្គលក្នុងនាមជាសមាគតពាក់ព័ន្ធ បើសិនអ្នកជឿជាក់ថាអត្ថគាហក/អ្នកផ្ញើប្រាក់នៅក្នុងប្រតិបត្តិការនោះបានសមគំនិតក្នុងសកម្មភាពសង្ស័យ។

សូមពន្យល់ពីសកម្មភាពសង្ស័យដែលកើតឡើង ឬនឹងកើតឡើង បើសិនជាសកម្មភាពនោះមិនទាក់ទងនឹងប្រតិបត្តិការហិរញ្ញវត្ថុ។

នៅលើទម្រង់របាយការណ៍ប្រតិបត្តិការសង្ស័យអេឡិចត្រូនិក មានកន្លែងសម្រាប់បញ្ចូលឯកសារប្រតិបត្តិការហិរញ្ញវត្ថុ និងសូមបំពេញទម្រង់ទាំងនោះឱ្យបានត្រឹមត្រូវជាការចាំបាច់។

**៧- លេខសម្គាល់បុគ្គលរាយការណ៍**

សំដៅដល់លេខសម្គាល់បុគ្គលរាយការណ៍។ ចំណុចនេះត្រូវបំពេញឲ្យបានត្រឹមត្រូវ ព្រោះអាចជួយឲ្យ ស.ហ.ក ធ្វើការវិភាគដែលមានប្រយោជន៍ជារួមសម្រាប់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងការរាយការណ៍ប្រតិបត្តិការសង្ស័យ។

### ៨- ឯកសារភ្ជាប់

ឯកសារដែលពាក់ព័ន្ធអាចបញ្ជូនភ្ជាប់ជាមួយរបាយការណ៍ប្រតិបត្តិការសង្ស័យបាន។

### ៩- ដីកាតុលាការ និងការសាកសួរពីភ្នាក់ងារអនុវត្តច្បាប់

នៅក្នុងករណីខ្លះ បុគ្គលរាយការណ៍នឹងទទួលបានដីកាពីតុលាការ (ដូចជាបញ្ជាឲ្យបញ្ចេញកំណត់ត្រា ឬឯកសារពាក់ព័ន្ធ) តាមសមត្ថកិច្ចជាក់លាក់រៀងខ្លួន។ ដីកានេះនឹងក្លាយជាយន្តការសម្រាប់បុគ្គលរាយការណ៍ ដើម្បីទៅពិនិត្យឡើងវិញពីសកម្មភាពដែលបានធ្វើកន្លងមកជាមួយបុគ្គល ឬអង្គភាពណាមួយ។ នៅពេលពិនិត្យឡើងវិញ បុគ្គលរាយការណ៍អាចរាយការណ៍ប្រតិបត្តិការសង្ស័យមក ស.ហ.ក បាន ប្រសិនបើជឿជាក់ថាមានកាតព្វកិច្ចបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យអំពី 'ជនជាកម្មវត្ថុនៃការសង្ស័យ'។

## ផ្នែកទី៣៖ សេចក្តីណែនាំទូទៅ

### ១- ការបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យ

យោងតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០០៧ ចែងថា បុគ្គលរាយការណ៍ទាំងអស់ ត្រូវបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យមក ស.ហ.ក។ ដើម្បីឱ្យស្របនឹងកាតព្វកិច្ចរាយការណ៍ បុគ្គលរាយការណ៍មិនត្រូវបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យទៅអាជ្ញាធរអនុវត្តច្បាប់ណាផ្សេងឡើយ ។

របាយការណ៍ប្រតិបត្តិការសង្ស័យដែលវិភាគរួច ស.ហ.ក នឹងបញ្ជូនទៅអាជ្ញាធរអនុវត្តច្បាប់តាមសមត្ថកិច្ចរៀងៗខ្លួន។ ដូច្នេះ ការបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យដូចគ្នាទៅអាជ្ញាធរអនុវត្តច្បាប់ផង និងមក ស.ហ.ក នឹងបង្កើតការងារជាន់គ្នាដែលអាចប៉ះពាល់ដល់ការរក្សាការសម្ងាត់ក៏ដូចជាសកម្មភាពការងាររបស់អាជ្ញាធរអនុវត្តច្បាប់ផងដែរ។

### ២- ចំណុចត្រូវចងចាំ

- មិនត្រូវប្រើប្រាស់របាយការណ៍ប្រតិបត្តិការសង្ស័យសម្រាប់ស្នើសុំការប្រឹក្សាយោបល់ឡើយ។ របាយការណ៍ប្រតិបត្តិការសង្ស័យ ត្រូវប្រើសម្រាប់តែការរាយការណ៍អំពីសកម្មភាពសង្ស័យមក ស.ហ.ក ប៉ុណ្ណោះ។ ប្រសិនបើអ្នកចង់បានការណែនាំទូទៅអំពីការសម្អាតប្រាក់ ឬការរាយការណ៍ប្រតិបត្តិការសង្ស័យ សូមទំនាក់ទំនងបញ្ជាក់បន្ថែមមក ស.ហ.ក។
- ស.ហ.ក មិនមានតួនាទីផ្តល់យោបល់ឲ្យបុគ្គលរាយការណ៍អំពីវិធីសាស្ត្រដែលអាចជួយឲ្យពួកគេកាត់បន្ថយហានិភ័យ ឬចង្អុលបង្ហាញថាទ្រព្យសម្បត្តិនោះមែន ឬមិនមែនជាផលនៃបទល្មើស ឬហិរញ្ញប្បទានភេរវកម្មឡើយ។
- សូមបំពេញព័ត៌មានពាក់ព័ន្ធដែលអ្នកបានដឹងទៅក្នុងកន្លែងបំពេញឲ្យបានត្រឹមត្រូវ។
- ត្រូវប្រាកដថា រាល់ព័ត៌មានដែលអ្នកបានបញ្ជូនមានភាពត្រឹមត្រូវនឹងអាចជួយដល់អាជ្ញាធរអនុវត្តច្បាប់ក្នុងការបំពេញការងារឱ្យមានប្រសិទ្ធភាព ត្រូវផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធឈ្មោះ និងព័ត៌មានគណនីឱ្យបានត្រឹមត្រូវ។
- បើសិនអ្នកមិនបានដឹងព័ត៌មានលម្អិតរបស់អង្គភាពណាមួយ ដូចជា អាសយដ្ឋានកាលបរិច្ឆេទចុះបញ្ជីជាដើម សូមកុំទុកចន្លោះចោល ត្រូវបំពេញថា "N/A"។

- សូមកុំបញ្ចូលព័ត៌មានលម្អិតរបស់មន្ត្រីរាយការណ៍ទៅក្នុងរបាយការណ៍ប្រតិបត្តិការសង្ស័យ។

**៤/- ផ្នែកទី៤៖ ព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងការបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យ សូមទំនាក់ទំនងមក ស.ហ.ក តាមរយៈ៖

- **អាសយដ្ឋាន៖** អគារលេខ ២២-២៤ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- **ទូរស័ព្ទ៖** (៨៥៥-២៣) ៤២៧ ៩៣៣
- **អ៊ីមែល៖** cafiu_request@nbc.org.kh

**៥/- ផ្នែកទី៥៖ គន្លឹះសម្រាប់អនុវត្តឱ្យបានល្អប្រសើរ**

**ក្នុងការរាយការណ៍ប្រតិបត្តិការសង្ស័យ ជានិច្ចកាល បុគ្គលរាយការណ៍ត្រូវ៖**

- កំណត់ឱ្យបានច្បាស់លាស់នូវផលនៃបទល្មើសដែលសង្ស័យ បានមកពីការប្រព្រឹត្តបទឧក្រិដ្ឋ (ទ្រព្យសម្បត្តិរបស់ជនល្មើស) រួមបញ្ចូលទាំងប្រាក់ចំណេញដែលបានពីផលនៃបទល្មើសផង បើអាចធ្វើទៅបាន
- កំណត់មូលហេតុនៃការសង្ស័យថាទ្រព្យសម្បត្តិ គឺជាទ្រព្យសម្បត្តិជនល្មើស
- កំណត់សកម្មភាពហាមឃាត់ដែលបានអនុវត្តពាក់ព័ន្ធនឹងទ្រព្យសម្បត្តិជនល្មើស
- កំណត់អត្តសញ្ញាណភាគីផ្សេងៗដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិជនល្មើស រួមមាន ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានដែលសមស្រប (បុគ្គលរាយការណ៍គួរតែប្រមូលព័ត៌មានទាំងនេះជាប្រចាំតាមវិស័យរបស់ខ្លួន ដើម្បីបំពេញតាមតម្រូវការបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់)
- ពិពណ៌នាឱ្យបានពេញលេញ អំពីមូលហេតុសង្ស័យទាក់ទងនឹងការសម្អាតប្រាក់។ បុគ្គលរាយការណ៍អាចព្យាយាមឆ្លើយសំណួរជាមូលដ្ឋានទាំងនេះ តាមដែលអាចធ្វើទៅបាន ទើបរបាយការណ៍ប្រតិបត្តិការសង្ស័យ រឹតតែមានប្រយោជន៍៖ នរណា? អ្វី? កន្លែងណា? ពេលណា? ហេតុអ្វី? ធ្វើដូចម្ដេច?

**ប្រសិនបើរបាយការណ៍ប្រតិបត្តិការសង្ស័យពាក់ព័ន្ធនឹងការទិញ / លក់ អចលនទ្រព្យសូមរាប់បញ្ចូល៖**

- អាសយដ្ឋានពេញលេញនៃអចលនទ្រព្យ
- តម្លៃរបស់អចលនទ្រព្យ
- កាលបរិច្ឆេទនៃសកម្មភាព
- របៀបដែលសកម្មភាពនឹងកើតឡើង ឬបានកើតឡើង
- អត្តសញ្ញាណពេញលេញរបស់ភាគីផ្សេងទៀត ដែលពាក់ព័ន្ធនឹងអចលនទ្រព្យ ប្រសិនបើមាន ជាពិសេស ប្រសិនបើពួកគេកំពុងផ្ដល់សេវាកម្មជំនាញវិជ្ជាជីវៈ

ឧទាហរណ៍ មេធាវី ភ្នាក់ងារអចលនទ្រព្យ គណនេយ្យករ ឬភ្នាក់ងារបង្កើតក្រុមហ៊ុនជាដើម។

**ប្រសិនបើរបាយការណ៍ប្រតិបត្តិការសង្ស័យពាក់ព័ន្ធនឹងបុគ្គលដែលងាយរងគ្រោះ៖**

- ពិពណ៌នាអំពីភាពងាយរងគ្រោះ ដែលអ្នកជឿជាក់ថាបុគ្គលមិនអាចការពារខ្លួនគាត់ពីការកេងប្រវ័ញ្ច ឧទាហរណ៍ អ្នកបារម្ភថាបុគ្គលនោះមានបញ្ហាខ្វះសតិ ពិការផ្លូវកាយ ឬមានជម្ងឺអ្វីមួយ?
- ពិពណ៌នាបញ្ជាក់ឲ្យច្បាស់ ប្រសិនបើមានភ្នាក់ងារអនុវត្តច្បាប់ ឬភ្នាក់ងារផ្សេងទៀតបានដឹងអំពីសកម្មភាពនេះ (សូមរាប់បញ្ចូលលេខយោងរបស់អង្គភាព និងព័ត៌មានលម្អិតរបស់មន្ត្រីទំនាក់ទំនងជាដើម)។

**ប្រសិនបើរបាយការណ៍ប្រតិបត្តិការសង្ស័យពាក់ព័ន្ធនឹងអ្នកជំនាញវិជ្ជាជីវៈ៖**

- ពិពណ៌នាអំពីសេវាដែលបានផ្តល់ ឧទាហរណ៍ដូចជា ជម្រះបញ្ជីគណនេយ្យ សវនកម្ម ការបង្កើតក្រុមហ៊ុន ការចុះបញ្ជីអចលនទ្រព្យ និងសេវាកម្មច្បាប់ ជាដើម រួមមាន៖
  - កាលបរិច្ឆេទនៃសកម្មភាព
  - របៀបដែលសកម្មភាពនឹងកើតឡើងឬបានកើតឡើង
  - អត្តសញ្ញាណពេញលេញរបស់ភាគីផ្សេងទៀត ដែលពាក់ព័ន្ធនឹងអចលនទ្រព្យ ប្រសិនបើមាន ជាពិសេស ប្រសិនបើពួកគេកំពុងផ្តល់សេវាកម្មជំនាញវិជ្ជាជីវៈ ឧទាហរណ៍ មេធាវី ភ្នាក់ងារអចលនទ្រព្យ គណនេយ្យករ ឬភ្នាក់ងារបង្កើតក្រុមហ៊ុនជាដើម។
- ពិពណ៌នាអំពីការសង្ស័យដែលទាក់ទងទៅនឹងសេវាកម្ម ដែលទំនងជាធ្វើដោយចេតនា ឬអចេតនា ដែលបានជួយសម្របសម្រួលដល់ការសម្អាតប្រាក់។
- រៀបរាប់ពីសូចនាករដែលបង្ហាញពីអាកប្បកិរិយាសមគំនិតជាមួយជនល្មើស ឬការធ្វេសប្រហែសរបស់អ្នកជំនាញដែលពាក់ព័ន្ធទាំងនោះ។

**ការផ្តល់យោបល់ឆ្លើយតបលើគុណភាពនៃការរាយការណ៍ប្រតិបត្តិការសង្ស័យ**

- យោងតាមមាត្រា ២១ (ច) នៃច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០០៧ បានចែងថា សក.ហ. ត្រូវផ្តល់យោបល់ចំពោះបុគ្គលរាយការណ៍ និងភ្នាក់ងារពាក់ព័ន្ធនានាទាក់ទងនឹងលទ្ធផលប្រតិបត្តិការសង្ស័យ ឬព័ត៌មានដែលបានផ្តល់មក ស.ហ.ក ដើម្បីកែលម្អគុណភាពនៃការរាយការណ៍។
- មតិយោបល់អាចត្រូវបានបញ្ជូនតាមរយៈទូរស័ព្ទ ឬទម្រង់ជាលាយលក្ខណ៍អក្សរដល់មន្ត្រីប្រតិបត្តិរបស់បុគ្គលរាយការណ៍។

**៦/- ផ្នែកទី៦៖ ឧទាហរណ៍**

**ខាងក្រោមនេះជាឧទាហរណ៍គំរូនៃរបាយការណ៍ប្រតិបត្តិការសង្ស័យ**

**<u>ឧទាហរណ៍ទី ១</u>** "យើងបានពិនិត្យឃើញថាការបង់ប្រាក់សរុបចំនួន ៥៦,០០០ ដុល្លារអាមេរិក បញ្ចូលទៅគណនីដែលមានលេខ XXXXXX ដែលបានធ្វើឡើងនៅ XXXX គឺជាការក្លែងបន្លំ។ យើងមានការព្រួយបារម្ភថា ម្ចាស់គណនីប្រហែលជាចូលរួមក្នុងការបោកបញ្ឆោត"។

តើអ្វីដែលធ្វើឱ្យអ្នករាយការណ៍មានការសង្ស័យថាប្រតិបត្តិការនេះជាការក្លែងបន្លំ? តើអ្នករាយការណ៍ដឹងដោយរបៀបណាថាម្ចាស់គណនីគឺជាអ្នកសមគំនិត? តើពួកគេធ្លាប់បានឃើញគំរូនេះពីមុនមកពាក់ព័ន្ធជាមួយអតិថិជននេះដែរឬទេ? តើមានព័ត៌មានផ្សេងទៀតដែលពន្យល់ថាហេតុអ្វីពួកគេគឺជាអ្នកសមគំនិតគ្នាឬទេ?

<u>ឧទាហរណ៍ទី ២</u> "យើងគឺជាគណនេយ្យកររបស់លោក Z ហើយពិនិត្យឃើញមានបញ្ហាក្នុងការរៀបចំគណនី។"

តើបញ្ហាអ្វីដែលគណនេយ្យករបានដឹងហើយ រឿងនេះកើតឡើងនៅពេលណា? តើមានការពិភាក្សាជាមួយអតិថិជនអំពីបញ្ហានេះដែរឬទេ? តើមានភាពមិនប្រក្រតីណាមួយកើតឡើងពីមុនដែរឬទេ? តើមានអាជីវកម្មដែលពាក់ព័ន្ធឬទេ? តើមានការសង្ស័យថាការសម្អាតប្រាក់កំពុងតែកើតឡើងដែរឬទេ? តើមានហេតុផលសមស្របសម្រាប់ធ្វើការសង្ស័យពាក់ព័ន្ធនឹងហិរញ្ញប្បទានភេរវកម្មឬទេ?

<u>ឧទាហរណ៍ទី ៣</u> "មានព័ត៌មានធ្វើឱ្យយើងចាប់អារម្មណ៍ថា 'ជនជាកម្មវត្ថុនៃការសង្ស័យ' ត្រូវបានផ្តន្ទាទោសពីបទល្មើសជួញដូរគ្រឿងញៀន។"

តើអ្នករាយការណ៍មានការចាប់អារម្មណ៍ព័ត៌មាននេះយ៉ាងដូចម្តេច? តើអ្នករាយការណ៍ចាប់អារម្មណ៍លើព័ត៌មាននេះនៅពេលណា? តើអ្នករាយការណ៍បានធ្វើអ្វីខ្លះសម្រាប់អតិថិជននេះ? តើមានការសង្ស័យឬភាពមិនប្រក្រតីអ្វីផ្សេងទៀតក្រៅពីការចោទប្រកាន់ឬទេ? តើអ្វីទៅជាការសង្ស័យ? តើមានការសង្ស័យពាក់ព័ន្ធនឹងការសម្អាតប្រាក់ឬមានការសង្ស័យណាមួយ ទាក់ទងនឹងហិរញ្ញប្បទានភេរវកម្មឬទេ?

<u>ឧទាហរណ៍ទី ៤</u> "ខ្ញុំមានការសង្ស័យដោយសារប៉ូលីសបានជូនដំណឹងដល់ផ្នែកប្រឆាំងបទល្មើសហិរញ្ញវត្ថុរបស់យើងខ្ញុំថា អតិថិជនរបស់យើងខ្ញុំកំពុងប្រើអត្តសញ្ញាណក្លែងក្លាយ។ ដូច្នេះ យើងខ្ញុំក៏បញ្ជូន របាយការណ៍ប្រតិបត្តិការសង្ស័យ"

តើអ្នករាយការណ៍មានទំនាក់ទំនងយ៉ាងណាជាមួយបុគ្គលសង្ស័យ? តើអ្នករាយការណ៍បានពិនិត្យគណនីឡើងវិញដែរឬទេ? តើអ្នករាយការណ៍មានការជឿជាក់ថាអតិថិជនបានប្រើប្រាស់ព័ត៌មានមិនពិតដើម្បីបើកគណនីនេះឬទេ?

<u>ឧទាហរណ៍ទី ៥</u> "មូលហេតុនៃការរាយការណ៍៖ របាយការណ៍បង្ហាញការបង់ប្រាក់ធំៗ ទៅក្រុមហ៊ុន Y ។ ប្រតិបត្តិការដែលមានទំហំធំបានបន្តកើតឡើងក្នុងរយៈពេលជាច្រើនខែ។ ការចំណាយលើការប្រើប្រាស់ផ្ទាល់ខ្លួនខ្ពស់ពេក និងញឹកញាប់ទៀត។ អាចជាការចំណាយសម្រាប់អាជីវកម្ម។"

ហេតុអ្វីបានជាអ្នករាយការណ៍បញ្ជូនរបាយការណ៍នេះ? តើអ្នករាយការណ៍មានការសង្ស័យថាអតិថិជនរបស់ពួកគេពាក់ព័ន្ធនឹងការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្មឬទេ? មើលទៅហាក់ដូចជាអតិថិជនកំពុងប្រើគណនីផ្ទាល់ខ្លួនសម្រាប់ការធ្វើអាជីវកម្ម។ វាមិនទំនងជាស្ថិតនៅក្រោមនីតិការណាមួយទេ តែទំនងជាកិច្ចសន្យាមានបញ្ហា ជាជាងការប្រព្រឹត្តបទល្មើស ឬការសម្អាតប្រាក់។

គ្រឹះស្ថានខ្លះបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យ ក្នុងគោលដៅខុស ដូចជា ការប្រើប្រាស់គណនីធនាគារខុស ឧទាហរណ៍ គណនីផ្ទាល់ខ្លួនប្រើសម្រាប់អាជីវកម្ម។ ស.ហ.ក នឹងមិនមានចំណាត់ការបន្តលើរបាយការណ៍ប្រតិបត្តិការសង្ស័យប្រភេទនេះទៅអាជ្ញាធរអនុវត្តច្បាប់ទេ។

<u>ឧទាហរណ៍ទី ៦</u> "មូលហេតុនៃការសង្ស័យរបស់ខ្ញុំគឺដោយសារមានការផ្ទេរប្រាក់របស់តតិយជនជាច្រើនចូលទៅក្នុងគណនីនោះ។ ទឹកប្រាក់ដែលបានផ្ទេរចូលនោះត្រូវបានដកជាច្រើនសារ។ ទឹកប្រាក់ទាំងនោះត្រូវបានបំបែកទៅឱ្យភាគីទីបីជាច្រើននាក់ទៀត។ ប្រភពនៃមូលនិធិដែលត្រូវបានផ្ទេរចូលទៅក្នុងគណនីនេះគឺអនាមិក ដែលជាហេតុធ្វើឱ្យខ្ញុំមានការសង្ស័យ។"

**អ្នករាយការណ៍មិនបានផ្ដល់មូលហេតុដែលខ្លួនបារម្ភទេ។ តើបានទាក់ទងទៅអតិថិជនឬទេ? ប្រសិនបានទាក់ទង តើអតិថិជនឆ្លើយតបដូចម្ដេច? តើការផ្ទេរប្រាក់ធ្វើឡើងពីពេលណា? តើការផ្ទេរម្ដងៗមានបរិមាណទឹកប្រាក់ប៉ុន្មាន? តើបន្ទាប់ពីផ្ទេរចូលរួចហើយ អតិថិជនបានដកប្រាក់ចេញពីគណនីរហ័សប៉ុណ្ណា?**

<u>ឧទាហរណ៍ទី៧</u> "យើងខ្ញុំកំពុងធ្វើប្រតិបត្តិការឱ្យ 'ជនជាកម្មវត្ថុនៃការសង្ស័យ' ក្នុងការផ្ដល់បុនហិរញ្ញប្បទានអចលនទ្រព្យរបស់គាត់។"

**គ្មានព័ត៌មានលម្អិត អំពីមូលហេតុដែលបានធ្វើឱ្យអ្នករាយការណ៍សង្ស័យអំពីរឿងនេះ។ តើការសង្ស័យទាក់ទងនឹងបុគ្គលសង្ស័យឬទេ? តើទ្រព្យសម្បត្តិរបស់បុគ្គលសង្ស័យមានតម្លៃប៉ុន្មាន? តើអាសយដ្ឋាននៃទ្រព្យសម្បត្តិនៅឯណា?**

<u>ឧទាហរណ៍ទី៨</u> "ឯកសារដែលត្រូវបានបង្ហាញនៅតុលាការ។"

**ឯកសារគ្មានការពន្យល់ ឬការបញ្ជាក់ច្បាស់លាស់។ ក្នុងនោះមានអ្វីដែលធ្វើឱ្យមានការសង្ស័យឬទេ? តើចំនួនអចលនទ្រព្យរបស់បុគ្គលសង្ស័យមានតម្លៃប៉ុន្មាន?**

**សេចក្ដីណែនាំនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។**

ថ្ងៃចន្ទ ១រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព២៥៦២.ស.

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

**អគ្គលេខាធិការ**

**សាយ សំអាត**

**ឧបសម្ព័ន្ធ**

## សេចក្តីសង្ខេបអំពីលក្ខណៈនៃរបាយការណ៍ប្រតិបត្តិការសង្ស័យដែលមានគុណភាពល្អ

| ល.រ | លក្ខណៈវិនិច្ឆ័យ | ការពិពណ៌នា |
|---|---|---|
| ១ | សម្គាល់អត្តសញ្ញាណបានគ្រប់គ្រាន់អំពី 'ជនជាកម្មវត្ថុនៃការសង្ស័យ' ក្នុង STR | ព័ត៌មានអត្តសញ្ញាណបន្ថែមក្នុងរបាយការណ៍ អាចកំណត់អត្តសញ្ញាណបុគ្គលសង្ស័យបានច្បាស់លាស់ |
| ២ | ព័ត៌មានអំពីមុខរបរ /និយោជក ជាព័ត៌មានបច្ចុប្បន្នភាព | ព័ត៌មានអំពីការងាររបស់បុគ្គល ឬនិយោជកនៅក្នុងរបាយការណ៍ជាព័ត៌មានបច្ចុប្បន្នភាព |
| ៣ | ពិពណ៌នាបានច្បាស់លាស់អំពីប្រតិបត្តិការ | ជាប្រតិបត្តិការដែលបានអធិប្បាយយ៉ាងច្បាស់លាស់អំពីបរិមាណ ប្រភេទជាដើម។ល។ |
| ៤ | បង្ហាញអំពីពេលវេលានៃសកម្មភាពហិរញ្ញវត្ថុ | ពេលវេលាត្រូវបានកំណត់យ៉ាងច្បាស់លាស់ជុំវិញសកម្មភាពប្រតិបត្តិការ "គួរឱ្យសង្ស័យ" |
| ៥ | បង្ហាញសូចនាករនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | របាយការណ៍ត្រូវបង្ហាញអំពីសូចនាករនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម |
| ៦ | បានកំណត់សម្គាល់នៃបទល្មើសជាសក្តានុពល ប្រសិនបើបានដឹង | ការពិពណ៌នាក្នុងរបាយការណ៍អាចកំណត់អំពីសម្គាល់នៃបទល្មើសជាសក្តានុពលនៃការសម្អាតប្រាក់ (ឧ. ការក្លែងបន្លំ ការជួញដូរគ្រឿងញៀនជាដើម។ល។) |
| ៧ | ភាគីពាក់ព័ន្ធផ្សេងទៀតត្រូវបានកំណត់អត្តសញ្ញាណបានគ្រប់គ្រាន់ | ការពិពណ៌នាក្នុងរបាយការណ៍អាចកំណត់បានអំពីអត្ត-សញ្ញាណនៃភាគីដែលពាក់ព័ន្ធនឹងប្រតិបត្តិការនោះបានអស់លទ្ធភាពដោយបុគ្គលរាយការណ៍ |
| ៨ | បានកំណត់ទំនាក់ទំនងអាជីវកម្ម ឬទំនាក់ទំនងផ្ទាល់ខ្លួនយ៉ាងច្បាស់ | ការពិពណ៌នាក្នុងរបាយការណ៍អាចកំណត់អំពីទំនាក់ទំនងរវាងបុគ្គលនិង/ឬ នីតិបុគ្គល បានអស់លទ្ធភាពដោយបុគ្គលរាយការណ៍ |

ការរាយការណ៍ព័ត៌មានលម្អិតរបស់អតិថិជនបានពេញលេញ និងមានសង្គតភាព (ឈ្មោះ អាសយដ្ឋាន ឯកសារអត្តសញ្ញាណ ថ្ងៃខែឆ្នាំកំណើតជាដើម។ល។) ធានាបានថា ស.ហ.ក មានព័ត៌មានជាក់លាក់ ដើម្បីស្វែងរកទិន្នន័យដែលមានស្រាប់ ហើយកំណត់អត្តសញ្ញាណឱ្យបានត្រឹមត្រូវអំពីអ្នកប្រព្រឹត្តប្រតិបត្តិការហិរញ្ញវត្ថុផ្សេងៗ។ ស.ហ.ក អាចយោងព័ត៌មានពីប្រភពបើកចំហ (ឧ. ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន) បន្ថែមលើការវិភាគព័ត៌មានក្នុងរបាយការណ៍ប្រតិបត្តិការសង្ស័យមួយ ដើម្បីកំណត់ និងបញ្ជាក់អំពីទំនាក់ទំនងនានា។ បើអាចធ្វើទៅបាន ការបញ្ចូលការពិពណ៌នាលម្អិតអំពីសម្គាល់នៃបទល្មើសជាសក្តានុពលនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងមូលហេតុដែលបុគ្គលរាយការណ៍សង្ស័យអំពីប្រតិបត្តិការនោះ ពិតជាមានសារៈសំខាន់ណាស់ ក្នុងការជួយដល់អ្នកវិភាគរបស់ ស.ហ.ក។